**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ** ៤៨ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុងតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

## ជំពូកទី២
## បេសកកម្ម មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា២ .-**

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បំពេញបេសកកម្មជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើការដឹកនាំនិងគ្រប់គ្រងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្មនិងទឹកស្អាត នៃព្រះរាជាណាចក្រកម្ពុជា។

បេសកកម្មនេះត្រូវធ្វើឡើងតាមរយៈការរៀបចំនិងការអនុវត្តឱ្យបានត្រឹមត្រូវនូវគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលទាក់ទងនឹងការដឹកនាំនិងការគ្រប់គ្រងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្មនិងទឹកស្អាត។

**មាត្រា៣ .-**

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានមុខងារនិងភារកិច្ចដូចតទៅ៖

- ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ និងផែនការរួមរបស់រាជរដ្ឋាភិបាល ក្នុងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្មនិងទឹកស្អាត
- ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការដឹកនាំ សម្របសម្រួល និងតាមដានការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ និងផែនការអភិវឌ្ឍន៍ក្នុងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្មនិងទឹកស្អាត
- ដឹកនាំនិងគ្រប់គ្រងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមទាំងសិប្បកម្មនិងទឹកស្អាត នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- រៀបចំគោលនយោបាយនិងកម្មវិធីអភិវឌ្ឍន៍រោងចក្រ សហគ្រាសធុនតូចនិងមធ្យម សិប្បកម្មនិងទឹកស្អាត
- សម្របសម្រួល សហការ និងអនុវត្តការងារសិក្សាស្រាវជ្រាវ ពិសោធន៍ និងអភិវឌ្ឍបច្ចេកវិទ្យា វិទ្យាសាស្ត្រ នវានុវត្តន៍ ដើម្បីគាំទ្រនិងជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្មនិងទឹកស្អាត
- ជំរុញនិងគាំទ្រនវានុវត្តន៍បច្ចេកវិទ្យា តក្កកម្ម គ្រប់គំនិតផ្តួចផ្តើមថ្មីៗ រួមទាំងសហគ្រិនភាពក្នុងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្មនិងទឹកស្អាត
- គ្រប់គ្រង វាយតម្លៃ ទទួលស្គាល់ និងផ្តល់វិញ្ញាបនបត្រ ប្រកាសនីយបត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- រៀបចំ គ្រប់គ្រង និងផ្សព្វផ្សាយបច្ចេកវិទ្យានិងនវានុវត្តន៍
- រៀបចំ គ្រប់គ្រង និងផ្សព្វផ្សាយការងារស្តង់ដារូបនីយកម្មនិងការធានាគុណភាពផលិតផល
- ធ្វើជាអាណាព្យាបាលបច្ចេកទេសលើសហគ្រាសសាធារណៈនិងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលត្រូវបានបង្កើតឡើងនៅក្រោមសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- រៀបចំ គ្រប់គ្រង ផ្សព្វផ្សាយការងារមាត្រាសាស្ត្រ

- រៀបចំ គ្រប់គ្រង និងអនុវត្តនយោបាយផ្គត់ផ្គង់ទឹកស្អាតដល់ទីក្រុងនិងទីប្រជុំជន
- សហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងតំបន់ ស្ថាប័ន អង្គការជាតិនិងអន្តរជាតិនានា រួមទាំងវិស័យឯកជន ដើម្បីជំរុញអភិវឌ្ឍន៍វិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្មនិងទឹកស្អាត។

**មាត្រា៤ .-**

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានរចនាសម្ព័ន្ធដូចតទៅ៖

**ក- អង្គភាពថ្នាក់ជាតិ**

១- ខុទ្ទកាល័យរដ្ឋមន្ត្រី
២- អគ្គនាយកដ្ឋានកិច្ចការទូទៅ
៣- អគ្គនាយកដ្ឋានឧស្សាហកម្ម
៤- អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម
៥- អគ្គនាយកដ្ឋានទឹកស្អាត
៦- អគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៧- វិទ្យាស្ថានស្តង់ដារកម្ពុជា
៨- វិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៩- មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
១០- អគ្គាធិការដ្ឋាន
១១- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
១២- សាខាសមត្ថកិច្ចជំនាញរាជធានី ខេត្ត

**ខ- សហគ្រាសសាធារណៈឬគ្រឹះស្ថានសាធារណៈរដ្ឋបាល**

សហគ្រាសសាធារណៈឬគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**គ- អង្គភាពថ្នាក់ក្រោមជាតិ**

មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី ខេត្ត។

**មាត្រា៥ .-**

អគ្គនាយកដ្ឋាននិងវិទ្យាស្ថានដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិដឹកនាំដោយប្រធានមួយរូបមានឋានៈស្មើអគ្គនាយក និងអមដោយអនុប្រធានមួយចំនួនមានឋានៈស្មើអគ្គនាយករងជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

អគ្គាធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូបមានឋានៈស្មើអគ្គនាយក និងអមដោយអគ្គាធិការរងមួយចំនួនមានឋានៈស្មើអគ្គនាយករងជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

នាយកដ្ឋានដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

សាខាសមត្ថកិច្ចជំនាញរាជធានី ខេត្ត ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ ប្រធាននិងអនុប្រធានសាខាសមត្ថកិច្ច

ជំនាញរាជធានី ខេត្ត ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានី ខេត្ត ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

អង្គការលេខរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៦ ..**

ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពនានាក្រោមឱវាទរបស់អគ្គនាយកដ្ឋាន វិទ្យាស្ថាន មជ្ឈមណ្ឌល អគ្គាធិការដ្ឋាន សាខាសមត្ថកិច្ចជំនាញរាជធានី ខេត្ត និងអង្គភាពថ្នាក់ក្រោមជាតិនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

## ជំពូកទី៣
## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា៧ ..**

ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលមានកំណត់ក្នុងអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន អនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន និងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៤
## អគ្គនាយកដ្ឋានកិច្ចការទូទៅ

**មាត្រា៨ ..**

អគ្គនាយកដ្ឋានកិច្ចការទូទៅ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- គ្រប់គ្រងការងាររដ្ឋបាលនិងសម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់ជាតិ និងរវាងអង្គភាពថ្នាក់ជាតិនិងអង្គភាពថ្នាក់ក្រោមជាតិក្រោមឱវាទ និងអង្គភាពដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស
- រៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ជួយសម្រួលដល់ការងារគ្រប់គ្រងរបស់ក្រសួងទាំងថ្នាក់ជាតិនិងទាំងនៅអង្គភាពថ្នាក់ក្រោមជាតិ
- គ្រប់គ្រងយានដ្ឋាននិងយានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួង ព្រមទាំងធ្វើកម្មវិធីចំណាយនិងបែងចែកប្រេងឥន្ធនៈនិងគ្រឿងបន្លាស់
- ទទួលនិងបែងចែកសម្ភារៈ បរិក្ខារ ជូនដល់បណ្តាអង្គភាពថ្នាក់ក្រោមជាតិ
- គ្រប់គ្រងមន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដែលមិនមែនជាមន្ត្រីរាជការរបស់ក្រសួង ដោយទំនាក់ទំនងជាមួយក្រសួងមុខងារសាធារណៈ និងវាយតម្លៃសេចក្តីត្រូវការក្នុងការបណ្តុះបណ្តាល
- រៀបចំការងារបៀវត្ស ប្រាក់កម្រៃផ្សេងៗ និងរបបឧបត្ថម្ភសន្តិសុខសង្គម
- រៀបចំនិងអនុវត្តគោលនយោបាយបណ្តុះបណ្តាលដំបូងនិងបន្តដោយទំនាក់ទំនងជាមួយក្រសួងមុខងារសាធារណៈនិង/ឬធ្វើការអភិវឌ្ឍធនធានមនុស្សដោយសហការជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ
- លើកគម្រោងថវិការបស់ក្រសួងនិងតាមដានរំលឹកអំពីការអនុវត្តថវិកា

- ប្រមូលផ្តុំគ្រប់គ្រងនិងសម្របសម្រួលរាល់ការចំណាយរបស់ក្រសួងទៅតាមខ្ទង់ជំពូកថវិកា រួមទាំងការងារលទ្ធកម្មសាធារណៈ
- ប្រមូលចំណូលឱ្យបានសមស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំដែលបានកំណត់
- ប្រមូលផ្តុំសេចក្តីត្រូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំជួសជុលសម្ភារៈ និងបរិក្ខាររបស់ក្រសួង
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភណ្ឌ
- រៀបចំតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតពាក់ព័ន្ធវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្មនិងទឹកស្អាត
- ស្រាវជ្រាវ ដកស្រង់ ចងក្រង និងផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត និងសន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិ ពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យ សិប្បកម្មនិងទឹកស្អាត
- ណែនាំនិងតាមដានការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត និងសន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិ ពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្មនិងទឹកស្អាត
- ជាជំនួយការច្បាប់ក្នុងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្មនិងទឹកស្អាតសម្រាប់ថ្នាក់ដឹកនាំក្រសួងនិងបណ្តាអង្គភាពក្រោមឱវាទ និងអង្គភាពក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួង
- សម្របសម្រួលដោះស្រាយវិវាទក្នុងដែនសមត្ថកិច្ចរបស់ក្រសួង
- រៀបចំផែនការនិងតាមដានការអនុវត្តផែនការសហប្រតិបត្តិការទ្វេភាគី ពហុភាគីជាមួយស្ថាប័នជាតិ និងអន្តរជាតិ និងអាស៊ាន ពាក់ព័ន្ធវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្មនិងទឹកស្អាត ដោយសហការជាមួយអង្គភាពជំនាញ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងជាមួយលេខាធិការដ្ឋានអាស៊ាន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**មាត្រា៩ ._**

អគ្គនាយកដ្ឋានកិច្ចការទូទៅ មាននាយកដ្ឋានក្រោមឱវាទចំនួន៥ (ប្រាំ) ដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ
- នាយកដ្ឋាននីតិកម្ម
- នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន។

អគ្គនាយកដ្ឋានកិច្ចការទូទៅទទួលបន្ទុកសម្របសម្រួលជាមួយមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី ខេត្ត ដែលតំណាងឱ្យក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍នៅថ្នាក់ក្រោមជាតិ។

**មាត្រា១០ ._**

នាយកដ្ឋានរដ្ឋបាលបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅលើការងាររដ្ឋបាល។

នាយកដ្ឋានបុគ្គលិកបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅលើការងារបុគ្គលិក។

នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅលើការងារគណនេយ្យនិងហិរញ្ញវត្ថុ។

នាយកដ្ឋាននីតិកម្មបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅលើការងារនីតិកម្ម។

នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅលើការងារផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន។

## ជំពូកទី៥
## អគ្គនាយកដ្ឋានឧស្សាហកម្ម

**មាត្រា១១ .-**

អគ្គនាយកដ្ឋានឧស្សាហកម្ម មានតួនាទីនិងភារកិច្ចដូចតទៅៈ

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ និងផែនការរួមក្នុងវិស័យឧស្សាហកម្ម
- រៀបចំ គ្រប់គ្រង ផ្សព្វផ្សាយ និងអភិវឌ្ឍឧស្សាហកម្ម
- គ្រប់គ្រង អភិវឌ្ឍន៍ និងតម្រង់ទិសលើការងារបច្ចេកទេសនិងសុវត្ថិភាពឧស្សាហកម្ម
- រៀបចំ គ្រប់គ្រង និងផ្សព្វផ្សាយការងារបច្ចេកវិទ្យាឧស្សាហកម្ម
- គ្រប់គ្រងនិងអនុវត្តការវាយតម្លៃទទួលស្គាល់
- ត្រួតពិនិត្យ វាយតម្លៃទទួលស្គាល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម
- អនុវត្តគោលនយោបាយនិងផែនការក្នុងការការពារសិទ្ធិលើកម្មសិទ្ធិឧស្សាហកម្ម
- គ្រប់គ្រង វាយតម្លៃ និងទទួលស្គាល់តក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- គ្រប់គ្រង សម្របសម្រួល និងជំរុញចលនានិងការអភិវឌ្ឍផលិតភាពនៅកម្ពុជា
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**មាត្រា១២ .-**

អគ្គនាយកដ្ឋានឧស្សាហកម្ម មាននាយកដ្ឋានចំនួន៤ (បួន)និងមជ្ឈមណ្ឌលមួយមានថ្នាក់ស្មើនាយកដ្ឋានក្រោមឱវាទដូចខាងក្រោមៈ

- នាយកដ្ឋានកិច្ចការឧស្សាហកម្ម
- នាយកដ្ឋានបច្ចេកទេសនិងសុវត្ថិភាពឧស្សាហកម្ម
- នាយកដ្ឋានវាយតម្លៃទទួលស្គាល់
- នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម
- មជ្ឈមណ្ឌលផលិតភាពជាតិ។

**មាត្រា១៣ .-**

នាយកដ្ឋានកិច្ចការឧស្សាហកម្មបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មលើកិច្ចការឧស្សាហកម្ម។

នាយកដ្ឋានបច្ចេកទេសនិងសុវត្ថិភាពឧស្សាហកម្មបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មលើការងារបច្ចេកទេសនិងសុវត្ថិភាពឧស្សាហកម្ម។

នាយកដ្ឋានវាយតម្លៃទទួលស្គាល់បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មលើការងារវាយតម្លៃទទួលស្គាល់និងលើអង្គភាពវាយតម្លៃភាពអនុលោម។

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មលើការងារកម្មសិទ្ធិឧស្សាហកម្ម។

មជ្ឈមណ្ឌលផលិតភាពជាតិបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មលើការងារផលិតភាពជាតិ។

## ជំពូកទី៦
## អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម

**មាត្រា១៤ ._**

អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ និងផែនការរួមលើវិស័យសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម
- រៀបចំ គ្រប់គ្រង ផ្សព្វផ្សាយ និងអភិវឌ្ឍវិស័យសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម
- គាំទ្រនិងលើកស្ទួយសហគ្រិនភាពក្នុងវិស័យសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម
- សហប្រតិបត្តិការជាមួយបណ្តាប្រទេស ស្ថាប័ន អង្គការជាតិនិងអន្តរជាតិនានា ដើម្បីជំរុញអភិវឌ្ឍន៍សហគ្រាស ធុនតូចនិងមធ្យម និងសិប្បកម្ម
- ពិនិត្យ វាយតម្លៃ និងអនុម័តលើគម្រោងវិនិយោគឯកជន លើសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្មដោយផ្ទាល់ឬដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ
- ចុះបញ្ជីគ្រប់គ្រងនិងត្រួតពិនិត្យសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម
- លើកសំណើ សម្របសម្រួល និងពិនិត្យតាមដានការអនុវត្តការវិនិយោគសាធារណៈក្នុងវិស័យសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម
- រៀបចំប្រកាសអនុញ្ញាតឱ្យសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្មដំណើរការ
- វាយតម្លៃលើយថាប្រភេទនិងបរិមាណវត្ថុធាតុដើមប្រើប្រាស់របស់សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម តាមបទដ្ឋានបច្ចេកទេស
- រៀបចំបញ្ជីផលិតផលនៃសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម
- ផ្តល់លិខិតបញ្ជាក់នានាដែលពាក់ព័ន្ធនឹងផលិតកម្មរបស់សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**មាត្រា១៥ ._**

អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម មាននាយកដ្ឋានក្រោមឱវាទចំនួន៣ (បី) ដូចខាងក្រោម៖

- នាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម
- នាយកដ្ឋានកិច្ចការសិប្បកម្ម
- នាយកដ្ឋានផែនការនិងជំរុញការអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម។

**មាត្រា១៦ ._**

នាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យមបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម លើការងារសហគ្រាសធុនតូចនិងមធ្យម។

នាយកដ្ឋានកិច្ចការសិប្បកម្មបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម លើការងារសិប្បកម្ម។

នាយកដ្ឋានផែនការ និងជំរុញការអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម លើការងារផែនការនិងជំរុញដល់កិច្ចអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម។

## ជំពូកទី៧
## អគ្គនាយកដ្ឋានទឹកស្អាត

**មាត្រា១៧ .-**

អគ្គនាយកដ្ឋានទឹកស្អាត មានតួនាទីនិងភារកិច្ចដូចតទៅ៖

- កសាង តាក់តែង និងត្រួតពិនិត្យការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត គោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ ផែនការសកម្មភាព ផែនការមេ សម្រាប់ដឹកនាំគ្រប់គ្រងវិស័យទឹកស្អាត
- រៀបចំ តាក់តែង កំណត់ស្តង់ដាបច្ចេកទេស ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត គោលការណ៍ផ្សេងៗ ដើម្បីធានាប្រសិទ្ធភាពនៅក្នុងដំណើរការផ្គត់ផ្គង់ទឹកស្អាត
- រៀបចំនិងចាត់តាំងអនុវត្តផែនការសុវត្ថិភាពទឹក
- រៀបចំ ដឹកនាំ កសាងផែនការរយៈពេលខ្លី មធ្យម និងវែង របស់គ្រប់ប្រតិបត្តិករទឹកស្អាត ដើម្បីសម្រេចឱ្យបានទិសដៅរបស់រាជរដ្ឋាភិបាលលើវិស័យទឹកស្អាត
- សិក្សា ស្រាវជ្រាវ លើកគម្រោងវិនិយោគ ដើម្បីស្វែងរកការគាំទ្រពីដៃគូអភិវឌ្ឍន៍នានាសំដៅអភិវឌ្ឍវិស័យទឹកស្អាត
- ដឹកនាំត្រួតពិនិត្យគ្រប់ប្រតិបត្តិការទឹកស្អាតទីប្រជុំជន ដើម្បីធានាសុខុមាលភាពប្រជាជន អ្នកប្រើប្រាស់ និងការពារបរិស្ថានសង្គម
- រៀបចំចងក្រងឯកសារ បទពិសោធន៍នានា និងចាត់តាំងការបណ្តុះបណ្តាលជំនាញបច្ចេកទេស ដល់គ្រប់ប្រតិបត្តិករផលិតនិងផ្គត់ផ្គង់ទឹកស្អាត ដើម្បីរួមចំណែកដល់ប្រសិទ្ធភាពការងារផ្គត់ផ្គង់ទឹកស្អាត
- អនុវត្តនីតិវិធីនៃការផ្តល់ការអនុញ្ញាតឱ្យធ្វើអាជីវកម្មដល់គ្រប់ប្រតិបត្តិករសាធារណៈឬឯកជន ឬចម្រុះរដ្ឋ ដោយសិក្សា វិភាគ វិនិច្ឆ័យ ដើម្បីផ្តល់យោបល់ទៅផ្នែកពាក់ព័ន្ធលើឯកសារសិក្សាសមិទ្ធិលទ្ធភាព ដែលបានសិក្សានិងស្នើឡើងដោយវិនិយោគិនឬប្រតិបត្តិករផលិតនិងផ្គត់ផ្គង់ទឹកស្អាត និងសិក្សា វិភាគ វិនិច្ឆ័យ ដើម្បីផ្តល់យោបល់ទៅផ្នែកពាក់ព័ន្ធលើឯកសារស្នើសុំការអនុញ្ញាតជំនួស ដែលបានស្នើឡើងដោយប្រតិបត្តិករផលិតនិងផ្គត់ផ្គង់ទឹកស្អាត
- ធ្វើបញ្ញត្តកម្មសេដ្ឋកិច្ចនិងសង្គម ពិសេសបញ្ញត្តកម្មថ្លៃលក់ទឹកស្អាត ដើម្បីធានាការពារផលប្រយោជន៍គ្រប់ភាគីពាក់ព័ន្ធឱ្យមានសមធម៌ជាចាំបាច់
- កសាង សិក្សាកញ្ចប់ព័ត៌មាន ឯកសារដេញថ្លៃ ដើម្បីចាត់តាំងធ្វើការដេញថ្លៃជាសាធារណៈ ក្នុងការផ្តល់ការអនុញ្ញាតប្រកួតប្រជែង
- ផ្សព្វផ្សាយអំពីថ្លៃលក់ទឹកនិងថ្លៃសេវាផ្សេងៗ ដែលក្រសួងបានសម្រេចទៅដល់ប្រជាពលរដ្ឋ អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ
- ចូលរួមធ្វើអធិការកិច្ចបណ្តាមូលដ្ឋានផ្តល់សេវាទឹកស្អាត តាមកម្មវិធី ឬតាមពាក្យបណ្តឹងតវ៉ា ឬតាមការចាំបាច់
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**មាត្រា១៨ .-**

អគ្គនាយកដ្ឋានទឹកស្អាត មាននាយកដ្ឋានក្រោមឱវាទចំនួន៥ (ប្រាំ) ដូចខាងក្រោម៖

- នាយកដ្ឋានសរុបនិងព័ត៌មាន
- នាយកដ្ឋានផែនការនិងគ្រប់គ្រងទិន្នន័យ
- នាយកដ្ឋានគោលនយោបាយទឹកស្អាត

- នាយកដ្ឋានបច្ចេកទេសនិងគ្រប់គ្រងគម្រោង
- នាយកដ្ឋានបញ្ញត្តកម្មទឹកស្អាត។

**មាត្រា១៩ .-**

នាយកដ្ឋានសរុបនិងព័ត៌មានបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទឹកស្អាតលើការងាររដ្ឋបាល គ្រប់គ្រង អភិវឌ្ឍធនធានមនុស្ស និងគណនេយ្យ។

នាយកដ្ឋានផែនការនិងគ្រប់គ្រងទិន្នន័យបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទឹកស្អាតលើការងារផែនការនិងការគ្រប់គ្រងទិន្នន័យ ក្នុងវិស័យទឹកស្អាតទីប្រជុំជននៅទូទាំងប្រទេស។

នាយកដ្ឋានគោលនយោបាយទឹកស្អាតបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទឹកស្អាត លើការងាររៀបចំ តាក់តែង គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ក្នុងវិស័យទឹកស្អាតទីប្រជុំជននៅទូទាំងប្រទេស។

នាយកដ្ឋានបច្ចេកទេសនិងគ្រប់គ្រងគម្រោង បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទឹកស្អាតលើការងារ បច្ចេកទេស និងការងារកសាង គ្រប់គ្រង និងអនុវត្តគម្រោង ក្នុងវិស័យទឹកស្អាតទីប្រជុំជននៅទូទាំងប្រទេស។

នាយកដ្ឋានបញ្ញត្តកម្មទឹកស្អាត បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទឹកស្អាត លើការងារបញ្ញត្តកម្មក្នុងវិស័យទឹកស្អាតទីប្រជុំជននៅទូទាំងប្រទេស។

## ជំពូកទី៨
## អគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

**មាត្រា២០ .-**

អគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនទីបង្ហាញផ្លូវ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលបម្រើវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- រៀបចំ គ្រប់គ្រង របកគំហើញដោយវិទ្យាសាស្ត្រ ក្នុងគោលដៅបម្រើនិងអភិវឌ្ឍឱ្យផ្នែកបច្ចេកវិទ្យាក្នុងវិស័យឧស្សាហកម្ម ក៏ដូចជាវិស័យនានា ដែលមានតម្រូវការក្នុងការអនុវត្តដែលមានលក្ខណៈជាយុទ្ធសាស្ត្រ ជំរុញនិងគាំទ្របច្ចេកវិទ្យា នវានុវត្តន៍ តក្កកម្ម គ្រប់គំនិតផ្តួចផ្តើមថ្មីៗនៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាឌីជីថល ដែលបម្រើក្នុងវិស័យឧស្សាហកម្មនិងវិស័យផ្សេងទៀត
- ជំរុញបណ្តាញបញ្ញាសិប្បនិម្មិត មនុស្សយន្ត និងស្វ័យប្រវត្តិកម្ម
- រៀបចំការងារឧស្សាហកម្មអេឡិចត្រូនិក ផ្នែករឹងនិងផ្នែកទន់
- រៀបចំសួនបច្ចេកវិទ្យានិងសួននវានុវត្តន៍
- សហការនិងសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធដែលទទួលបន្ទុកការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជំរុញនិងបង្កើនការចូលរួមរបស់ឧស្សាហកម្ម ទំនុកបម្រុង និងបង្កើនសមត្ថភាពសហគ្រាសធុនតូចនិងមធ្យម ព្រមទាំងគាំទ្រសាជីវកម្មខ្នាតធំឱ្យមានសមត្ថភាពនវានុវត្តន៍កាន់តែខ្ពស់
- ពង្រឹងនិងសម្រួលសេវាសាធារណៈផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យាសំខាន់ៗ ដូចជាកិច្ចការដែលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាឧស្សាហកម្ម ស្តង់ដារជាតិសម្រាប់វិញ្ញាបនបត្រ និងការទទួលស្គាល់សម្បទានបច្ចេកវិទ្យាសកល
- ចូលរួមជាមួយស្ថាប័នវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍អន្តរជាតិ និងរួមគ្នាជួយជ្រោមជ្រែងបង្កើតនិងពង្រឹងបណ្តាញធនធានហិរញ្ញវត្ថុ បណ្តាញកសាងធនធានមនុស្ស

- រៀបចំយន្តការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគោលនយោបាយផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ជំរុញការងារបច្ចេកវិទ្យា ដែលមានលក្ខណៈ វៃឆ្លាត និងបញ្ញាសិប្បនិម្មិត បច្ចេកវិទ្យាអវកាស បច្ចេកវិទ្យាព័ត៌មានលម្អ និងប្រព័ន្ធអេកូនវានុវត្តន៍
- រៀបចំ ចាត់ចែង និងចូលរួមនូវរាល់ព្រឹត្តិការណ៍ទាំងឡាយពាក់ព័ន្ធនឹងការជំរុញ ការអភិវឌ្ឍ និងការផ្សព្វផ្សាយ ការងារឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**មាត្រា២១ ._**

អគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មាននាយកដ្ឋានក្រោមឱវាទចំនួន៥ (ប្រាំ) ដូចខាងក្រោម៖

- នាយកដ្ឋានគោលនយោបាយ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- នាយកដ្ឋានផ្ទេរបច្ចេកវិទ្យា
- នាយកដ្ឋានគ្រប់គ្រងព័ត៌មាន វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- នាយកដ្ឋានសហប្រតិបត្តិការវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ។

**មាត្រា២២ ._**

នាយកដ្ឋានគោលនយោបាយ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការងារគោលនយោបាយ បច្ចេកវិទ្យា និងនវានុវត្តន៍។

នាយកដ្ឋានផ្ទេរបច្ចេកវិទ្យា បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍លើការងារផ្ទេរបច្ចេកវិទ្យា។

នាយកដ្ឋានគ្រប់គ្រងព័ត៌មាន បច្ចេកវិទ្យា និងនវានុវត្តន៍ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការងារគ្រប់គ្រងព័ត៌មាន បច្ចេកវិទ្យា និងនវានុវត្តន៍។

នាយកដ្ឋានសហប្រតិបត្តិការវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការងារសហប្រតិបត្តិការវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ។

## ជំពូកទី៩
## វិទ្យាស្ថានស្តង់ដារកម្ពុជា

**មាត្រា២៣ ._**

វិទ្យាស្ថានស្តង់ដារកម្ពុជា មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំស្តង់ដាជាតិសម្រាប់ផលិតផល ទំនិញ សម្ភារៈ សេវាកម្ម ការអនុវត្តលើគ្រប់វិស័យ ប្រតិបត្តិការ និងផ្សព្វផ្សាយ
- អនុវត្តការវាយតម្លៃភាពអនុលោមស្របតាមបញ្ញត្តិ ដែលមានចែងក្នុងច្បាប់ស្តីពីស្តង់ដារកម្ពុជា

- បង្កើតនិងថែទាំមន្ទីរពិសោធន៍ បណ្ណាល័យ មធ្យោបាយ និងឧបករណ៍ផ្សេងទៀត ដើម្បីលើកកម្ពស់ស្តង់ដារូបនីយកម្មនិងគុណភាព
- បញ្ជាក់ភាពអនុលោមតាមស្តង់ដារសម្រាប់ផលិតផល ទំនិញ សារធាតុ សម្ភារៈ និងបរិក្ខារសម្រាប់ការប្រើប្រាស់ក្នុងប្រទេសឬសម្រាប់ការនាំចូលនាំចេញ តាមសំណើរបស់អ្នកស្នើសុំ
- បញ្ជាក់ភាពអនុលោមតាមស្តង់ដារសុវត្ថិភាពសម្រាប់ផលិតផល ទំនិញ សារធាតុ សម្ភារៈ និងបរិក្ខារសម្រាប់ការប្រើប្រាស់ក្នុងប្រទេសឬសម្រាប់ការនាំចូលនាំចេញ តាមសំណើរបស់អ្នកស្នើសុំ
- បញ្ជាក់ភាពអនុលោមតាមស្តង់ដារសម្រាប់ប្រព័ន្ធគ្រប់គ្រងផលិតកម្មនិងសេវាកម្មតាម សំណើរបស់អ្នកស្នើសុំ
- ចុះបញ្ជីផលិតផល បញ្ជាក់ភាពអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសឬស្តង់ដាបញ្ជាសម្រាប់ផលិតផល ទំនិញ សារធាតុ សម្ភារៈ និងបរិក្ខារសម្រាប់ការប្រើប្រាស់ក្នុងប្រទេស ឬសម្រាប់ការនាំចូលនាំចេញ តាមសំណើរបស់អ្នកស្នើសុំ
- រៀបចំនិងគ្រប់គ្រងស្តង់ដា និងបញ្ជាក់មុខសញ្ញានិង/ឬស្តង់ដាប្រើប្រាស់សារធាតុគីមីក្នុងវិស័យឧស្សាហកម្ម
- ព្យួរទុក ដកហូត និងលុបចោលអាជ្ញាប័ណ្ណប្រើសញ្ញាស្តង់ដាបញ្ជាក់ផលិតផល ឬវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមផលិតផល ឬវិញ្ញាបនបត្រចុះបញ្ជីផលិតផល ឬវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ
- ស្រាវជ្រាវអំពីស្តង់ដារូបនីយកម្ម
- ផ្តល់សេវាអប់រំ បណ្តុះបណ្តាល និងពិគ្រោះយោបល់ ដើម្បីផ្សព្វផ្សាយស្តង់ដារូបនីយកម្មនិងគុណភាព
- ទទួលស្គាល់អង្គភាពចេញវិញ្ញាបនបត្រ មន្ទីរពិសោធន៍ មធ្យោបាយ និងឧបករណ៍ផ្សេងទៀតរបស់អង្គភាពក្នុងនិងក្រៅប្រទេស សម្រាប់គោលបំណងរបស់វិទ្យាស្ថាន
- ផ្តល់កិច្ចសហប្រតិបត្តិការជាមួយបុគ្គល អង្គការអន្តរជាតិ ឬសមាគមបរទេស ដែលមានកម្មវត្ថុនិងគោលបំណងដូចគ្នា
- ជំរុញនិងលើកទឹកចិត្តការអនុវត្តស្តង់ដានិងស្តង់ដារូបនីយកម្មឱ្យទៅជាមធ្យោបាយមួយសម្រាប់ការរីកចម្រើន នៃសេដ្ឋកិច្ចជាតិ សម្រាប់សុខភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ
- សហការជាមួយអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធនឹងផ្នែកឧស្សាហកម្ម ពាណិជ្ជកម្ម និងអង្គការនានា ដើម្បីធានាការអនុវត្តស្តង់ដា
- វិភាគនិងធ្វើតេស្តផ្នែករូបសាស្ត្រ គីមីសាស្ត្រ មីក្រូជីវសាស្ត្រ មេកានិក ដើម្បីលើកកម្ពស់ស្តង់ដារូបនីយកម្មនិងគុណភាពផលិតផល
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**មាត្រា២៤ .-**

វិទ្យាស្ថានស្តង់ដារកម្ពុជា មាននាយកដ្ឋានក្រោមឱវាទចំនួន៤ (បួន) ដូចខាងក្រោម៖

- នាយកដ្ឋានព័ត៌មាន
- នាយកដ្ឋានអភិវឌ្ឍស្តង់ដារ បណ្តុះបណ្តាល និងពិគ្រោះយោបល់
- នាយកដ្ឋានវិញ្ញាបនបត្រកម្ម
- នាយកដ្ឋានបញ្ញត្តកម្ម។

**មាត្រា២៥ .-**

នាយកដ្ឋានព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានស្តង់ដារកម្ពុជា លើការងារព័ត៌មាន។

នាយកដ្ឋានអភិវឌ្ឍស្តង់ដារ បណ្តុះបណ្តាល និងពិគ្រោះយោបល់ បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានស្តង់ដារកម្ពុជា លើការងារអភិវឌ្ឍស្តង់ដា បណ្តុះបណ្តាល និងពិគ្រោះយោបល់។

នាយកដ្ឋានវិញ្ញាបនបត្រកម្ម បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានស្តង់ដារកម្ពុជា លើការងារវិញ្ញាបនបត្រកម្ម។

នាយកដ្ឋានបញ្ញត្តកម្ម បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានស្តង់ដារកម្ពុជា លើការងារបញ្ញត្តកម្ម និងអធិការកិច្ច។

## ជំពូកទី១០
## វិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

**មាត្រា២៦ .-**

វិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានថ្នាក់ស្មើអគ្គនាយកដ្ឋាន មានតួនាទីនិងភារកិច្ចដូចតទៅ៖

- សិក្សា ស្រាវជ្រាវការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យាឬបច្ចេកវិទ្យាឌីជីថល និងនវានុវត្តន៍ ក្នុងគោលដៅបម្រើឱ្យអន្តរវិស័យ ក្នុងនោះវិស័យឧស្សាហកម្ម៤.០ និងឧស្សាហកម្មជំនាន់ក្រោយបន្តបន្ទាប់ទៀត
- ជំរុញនិងលើកទឹកចិត្ត ក្នុងការសិក្សាស្រាវជ្រាវផ្នែកបណ្តាញបញ្ញាសិប្បនិម្មិត មនុស្សយន្ត និងស្វ័យប្រវត្តិកម្ម
- ជំរុញការងារសិក្សាស្រាវជ្រាវឧស្សាហកម្មអេឡិចត្រូនិក (ផ្នែករឹងនិងផ្នែកទន់)
- សហការស្រាវជ្រាវ ផ្នែកឧស្សាហកម្មបច្ចេកវិទ្យា (កសិឧស្សាហកម្ម ស្បៀងអាហារ និងជីវៈវេជ្ជសាស្ត្រ)
- សហការនិងស្រាវជ្រាវជាមូលដ្ឋានជាមួយក្រសួង ស្ថាប័ន និងអង្គការជាតិនិងអន្តរជាតិពាក់ព័ន្ធ
- សហការស្រាវជ្រាវនិងអភិវឌ្ឍន៍លើមូលដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា សម្រាប់ការសិក្សាអប់រំ
- សិក្សាស្រាវជ្រាវ ធ្វើតេស្ត និងពិសោធន៍វិទ្យាសាស្ត្រ លើផ្នែករូបសាស្ត្រនិងគីមីសាស្ត្រ
- រៀបចំ សហការ ដោយផ្តល់លទ្ធភាពដល់សកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍន៍ដែលទទួលបាន និងស្ថានភាពជាក់ស្តែងក្នុងប្រទេស សំដៅបង្កើនសមត្ថភាពក្រេបយកបច្ចេកវិទ្យាអន្តរជាតិ
- រៀបចំគម្រោងផែនការការងារជំរុញអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- រៀបចំ កែលម្អស្ថានភាពបណ្តុះបណ្តាលផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សំដៅអភិវឌ្ឍលើការសិក្សាអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបង្កើតបណ្តាញ និងបណ្តុំបញ្ញវន្តដែលផ្សារភ្ជាប់បណ្តាញឧស្សាហកម្មក្នុងនិងក្រៅប្រទេស
- រៀបចំនិងផ្តល់ការលើកទឹកចិត្តការស្រាវជ្រាវបឋម ការស្រាវជ្រាវអនុវត្តន៍ និងការអភិវឌ្ឍដោយពិសោធន៍
- រៀបចំសមាគមអ្នកស្រាវជ្រាវ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សំដៅប្រមូលផ្តុំអ្នកបច្ចេកទេស អ្នកវិទ្យាសាស្ត្រ បញ្ញវន្ត ដែលគាំទ្រដល់ការស្រាវជ្រាវនិងការអភិវឌ្ឍ
- រៀបចំការបណ្តុះបណ្តាលផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- រៀបចំនិងដំណើរការមន្ទីរពិសោធន៍ ស្រាវជ្រាវវិទ្យាសាស្ត្រ និងអភិវឌ្ឍបច្ចេកវិទ្យា
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**មាត្រា២៧ .-**

វិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មាននាយកដ្ឋានចំនួន៣ (បី) និងមន្ទីរពិសោធន៍មួយ ដែលមានថ្នាក់ស្មើនាយកដ្ឋានក្រោមឱវាទដូចខាងក្រោម៖

- នាយកដ្ឋានស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យា
- នាយកដ្ឋានជំរុញអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- នាយកដ្ឋានបណ្តុះបណ្តាលវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- មន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**មាត្រា២៨ ._**

នាយកដ្ឋានស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យា បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការងារសិក្សាស្រាវជ្រាវ ពិសោធន៍ និងអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

នាយកដ្ឋានជំរុញអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការងារជំរុញអភិវឌ្ឍន៍អ្នកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

នាយកដ្ឋានបណ្តុះបណ្តាលវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការងារបណ្តុះបណ្តាលលើវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

មន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា រួមមានការវិភាគ ការធ្វើតេស្ត និងពិសោធន៍ ផ្នែករូបសាស្ត្រ គីមីសាស្ត្រ មីក្រូជីវសាស្ត្រ មេកានិក និងពិសោធន៍គុណភាពផលិតផល និងកំណត់លក្ខណវិនិច្ឆ័យនៃផលិតផលក្នុងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្មនិងទឹកស្អាត ដើម្បីកំណត់គុណភាពលក្ខណវិនិច្ឆ័យ និងគោលដៅបម្រើឱ្យការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

## ជំពូកទី១១
## មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

**មាត្រា២៩ ._**

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ មានថ្នាក់ស្មើអគ្គនាយកដ្ឋាន មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសម្រាប់អភិវឌ្ឍន៍ផ្នែកមាត្រាសាស្ត្រ
- អនុវត្តការងារចុះបញ្ជីមាត្រាសាស្ត្រ សិក្សាស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា វិទ្យាសាស្ត្រមាត្រាសាស្ត្រ
- គ្រប់គ្រងនិងថែរក្សាស្តង់ដាគោលជាតិ ស្តង់ដាបន្ទាប់ និងស្តង់ដាប្រតិបត្តិ
- ពិនិត្យវាយតម្លៃលើភាពអនុលោមនិងផ្តល់វិញ្ញាបនបត្រទទួលស្គាល់ស្តង់ដាប្រតិបត្តិសម្រាប់ការអនុវត្តដល់អង្គភាពផ្សេងៗ
- ធ្វើតេស្ត វិភាគ និងអនុម័តគំរូជាក់លាក់ណាមួយនៃឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត ពុម្ព និងសំបកវេចខ្ចប់
- ធ្វើព្យាសកម្មស្តង់ដាមាត្រាសាស្ត្រនិងឧបករណ៍មាត្រាសាស្ត្រ
- ធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់និងបញ្ជាក់ភាពអនុលោមអំពីទម្ងន់និងរង្វាស់រង្វាល់ នៃទំនិញផលិតនិងទំនិញវេចខ្ចប់តាមលក្ខខណ្ឌលម្អិតនៃទំនិញវេចខ្ចប់ដែលទាក់ទងនឹងផ្នែកមាត្រាសាស្ត្រ
- ធ្វើការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបញ្ជាក់សមត្ថភាពអប្បបរមា និងអតិបរមាអំពីទម្ងន់និង/ឬរង្វាស់រង្វាល់នៃឧបករណ៍មាត្រាសាស្ត្រដែលអនុញ្ញាតឱ្យប្រើប្រាស់ឬកាន់កាប់បានក្នុងសកម្មភាពពាណិជ្ជកម្ម និងវិស័យផ្សេងៗទៀត ដោយផ្អែកលើប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់
- រៀបចំ សម្របសម្រួល និងគ្រប់គ្រងការបង្កើតនិងការប្រើប្រាស់ប្រព័ន្ធឯកតាមាត្រាសាស្ត្រស្របច្បាប់ និងប្រព័ន្ធឯកតាផ្សេងៗទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា

- ផ្តល់អាជ្ញាប័ណ្ណលើការផលិតនិងការជួសជុលឧបករណ៍មាត្រាសាស្ត្រ និងអាជ្ញាប័ណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជាស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន
- រៀបចំលិខិតបទដ្ឋានគតិយុត្តនានានិងនីតិវិធីរដ្ឋបាល បច្ចេកទេស ដើម្បីពង្រឹងប្រសិទ្ធភាពការងារមាត្រាសាស្ត្រ
- កសាងសមត្ថភាពធនធានមនុស្ស អភិវឌ្ឍបច្ចេកវិទ្យា ប្រព័ន្ធព័ត៌មានវិទ្យា និងអនុវត្តការវាយតម្លៃសមត្ថភាពបុគ្គលនិងអង្គភាពលើវិស័យមាត្រាសាស្ត្រ
- អនុវត្តការងារសហប្រតិបត្តិការជាមួយស្ថាប័នជាតិនិងអន្តរជាតិដើម្បីធ្វើសុខដុមនីយកម្មការងារមាត្រាសាស្ត្រ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ លើការត្រួតពិនិត្យបទល្មើសក្នុងការផលិត ការជួសជុល ការប្រើប្រាស់ និងការធ្វើពាណិជ្ជកម្ម ឧបករណ៍មាត្រាសាស្ត្រ ស្តង់ដាមាត្រាសាស្ត្រ និងការប្រើប្រាស់ប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់
- រៀបចំនិងគ្រប់គ្រងឧបករណ៍មាត្រាសាស្ត្រ ស្តង់ដាមាត្រាសាស្ត្រ ទំនិញផលិត ទំនិញវេចខ្ចប់ក្នុងប្រទេសនិងទំនិញនាំចូល
- គ្រប់គ្រងនិងអនុវត្តការងារប្រមូលថ្លៃសេវាកម្ម កម្រៃផ្សេងៗ និងការពិន័យ ស្របតាមការកំណត់នៃច្បាប់និងបទប្បញ្ញត្តិជាធរមាន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**មាត្រា៣០.-**

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ មាននាយកដ្ឋានក្រោមឱវាទចំនួន៤ (បួន) ដូចខាងក្រោម៖
- នាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ
- នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ
- នាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម
- នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ។

**មាត្រា៣១.-**

នាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ បំពេញមុខងារជាសេនាធិការឱ្យមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិលើការងារវិទ្យាសាស្ត្រមាត្រាសាស្ត្រ។

នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ បំពេញមុខងារជាសេនាធិការឱ្យមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិលើការងារនីត្យានុកូលមាត្រាសាស្ត្រ។

នាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម បំពេញមុខងារជាសេនាធិការឱ្យមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិលើការងារ មាត្រាសាស្ត្រឧស្សាហកម្ម។

នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ បំពេញមុខងារជាសេនាធិការឱ្យមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិលើការងារនីតិកម្មមាត្រាសាស្ត្រ។

## ជំពូកទី១២
## អគ្គាធិការដ្ឋាន

**មាត្រា៣២.-**

អគ្គាធិការដ្ឋាន មានតួនាទីនិងភារកិច្ចដូចតទៅ៖
- ធ្វើអធិការកិច្ចជាប្រចាំទៅលើការគ្រប់គ្រងអង្គភាពក្រោមឱវាទរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីអំពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចរួចហើយនិងអំពីមធ្យោបាយ កែលម្អការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

## ជំពូកទី១៣
## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា៣៣ .-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ និងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី១៤
## សាខាសមត្ថកិច្ចជំនាញរាជធានី ខេត្ត

**មាត្រា៣៤ .-**

សាខាសមត្ថកិច្ចជំនាញរាជធានី ខេត្តមានតួនាទីនិងភារកិច្ចដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការងារក្នុងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្មនិងទឹកស្អាត នៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

## ជំពូកទី១៥
## អង្គភាពថ្នាក់ក្រោមជាតិ

**មាត្រា៣៥ .-**

មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានតួនាទីនិងភារកិច្ចដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការងារលើវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្ម និងទឹកស្អាត នៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

## ជំពូកទី១៦
## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា៣៦ .-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមលក្ខខណ្ឌនៃបទបញ្ជាកំណត់ក្នុងអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង។

## ជំពូកទី១៧
## អន្តរប្បញ្ញត្តិ

**មាត្រា៣៧ .-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការតែងតាំងមន្ត្រីរាជការ ការបង្កើតឬការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពនានាចំណុះក្រសួងឧស្សាហកម្មនិងសិប្បកម្ម ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី១៨
## អវសានប្បញ្ញត្តិ

**មាត្រា៣៨ .-**

អនុក្រឹត្យលេខ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម អនុក្រឹត្យលេខ១៥៧ អនក្រ.បក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៤កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មេសា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ**

**បច្ចេកវិទ្យា និងនវានុវត្តន៍**

កិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# អង្គការលេខរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...៤៨...... អនក្រ.បក

ចុះថ្ងៃទី...៦.... ខែ...មេសា..... ឆ្នាំ២០២០

